# វិភាគបន្សំ និង ប្រូបាប

## I. គោលការណ៍រាប់

1. <u>គោលការណ៍ផលបូក</u>: ចំនួនលទ្ធផលនៃលព្រឹត្តិការណ៍ A ឬ B កើតឡើងគឺ $P=n(A)+n(B)$ បើ A និង B មិនទាក់ទងគ្នា ហើយ $P=n(A)+n(B)-n(A\cap B)$ បើ A និង B ទាក់ទងគ្នា។

2. <u>គោលការណ៍ផលគុណ</u>: បើព្រឹត្តិការណ៍ A កើតឡើង m របៀប ហើយមានព្រឹត្តិការណ៍ B កើតឡើង m របៀបទៀត នោះចំនួនលទ្ធផលនៃលព្រឹត្តិការណ៍ A និង B កើតឡើងពី $P=m\times n$ ។

<u>Note:</u> «ឬ»: បូក , «និង»: គុណ។

## II. <u>ហ្វាក់តូរីយែល</u>: $n!=n\times(n-1)\times(n-2)\times\ldots\times3\times2\times1$

$$n!=n\times(n-1)!=n\times(n-1)\times(n-2)!$$

## III. <u>ចម្លាស់</u>:

1. ចំនួនចម្លាស់ n ធាតុផ្សេងគ្នារៀបជាជួរដេក $P=n!$ ។

2. ចំនួនចម្លាស់រង្វង់នៃ n ធាតុផ្សេងគ្នា $P=\frac{n!}{n}=(n-1)!$ ។

3. ចំនួនចម្លាស់ច្រំដែលនៃ m ធាតុយកពី n ធាតុផ្សេងគ្នា: $P=n^m$ ។

4. ចំនួនចម្លាស់ m ធាតុយកពី n ធាតុផ្សេងគ្នា: $P(n,m)=\frac{n!}{(n-m)!}$ ។

5. ចំនួនចម្លាស់អាចបែងចែកបាន ឬចម្លាស់ដែលមានធាតុខ្លះដូចគ្នា

$$P=\frac{(n_1+n_2+n_3+\ldots+n_p)!}{n_1!\times n_2!\times n_3!\times\ldots\times n_p!}$$

## IV. <u>បន្សំ</u>:

**ចំនួនបន្សំនៃ m ធាតុយកពី n ធាតុផ្សេងគ្នា៖** $C(n,m)=\frac{n!}{(n-m)!\times m!}$ ។

## ប្រៀបធៀប

**ចម្លាស់**

$P(n,r)=\dfrac{n!}{(n-r)!}$

$AB \neq BA$ (គិតលំដាប់)

ជ្រើសរើសហើយទើបយកមករៀប

**បន្សំ**

$C(n,r)=\dfrac{n!}{r!(n-r)!}=\dfrac{P(n,r)}{r!}$

$AB = BA$ (មិនគិតលំដាប់)

គ្រាន់តែជ្រើសរើសតែមិនបានយកមកតំរៀបទេ

## V. ប្រូបាប:

**1. និយមន័យ:** ប្រូបាបនៃព្រឹត្តិការណ៍ $A$ ក្នុងលំហសំណាក $S$ កំណត់ដោយ $P(A)=\dfrac{n(A)}{n(S)}$ ។

**2. ប្រូបាបនៃព្រឹត្តិការណ៍សមាស :**

$P(A\cap B)=P(A)\times P(B)$ បើ $A$ និង $B$ មិនទាក់ទងគ្នា។

$P(A\cap B)=P(A)\times P(B/A)$ បើ $A$ និង $B$ ទាក់ទងគ្នា។

$P(A\cup B)=P(A)+P(B)-P(A\cap B)$ បើ $A$ និង $B$ ចុះសម្រុងគ្នា។

$P(A\cup B)=P(A)+P(B)$ បើ $A$ និង $B$ មិនចុះសម្រុងគ្នា។

$P(\overline{A})=1-P(A)$ ព្រឹត្តិការណ៍ $\overline{A}$ និង $A$ ផ្ទុយគ្នា។

*Note:* $P(\phi)=0, P(S)=1, 0\le P(A)\le 1$ ។

**3. ប្រូបាបមានលក្ខខណ្ឌ**

$$P(B/A)=\frac{P(A\cap B)}{P(A)},\ P(A)\neq 0$$

$$P(A/B)=\frac{P(A\cap B)}{P(B)},\ P(B)\neq 0$$

**4. រូបមន្តប្រូបាបសរុប** $\quad P(B)=\sum_{i=1}^{n}\left[P(B/A_i)\times P(A_i)\right]$

**5. ទ្រឹស្តីបទបៃយេស** $\quad P(A_k/B)=\dfrac{P(B/A_k)\times P(A_k)}{P(B)}$

# លំហាត់លើវិភាគបន្សំ និងប្រូបាប

១. គណនា $P(5,3),P(6,3),P(7,5),P(10,4)$ ។

២.គណនា $C(5,3),C(6,3),C(7,5),C(10,4)$ ។

៣. គេចង់ជ្រើសរើសយកសិស្ស 3 នាក់ក្នុងចំណោមសិស្ស 10 នាក់ដែលក្នុងនោះមានសិស្សប្រុស 6នាក់ និងសិស្សស្រី 4នាក់។ រកប្រូបាបដែលគេជ្រើសរើសបានសិស្សប្រុស 2នាក់ និងសិស្សស្រី 1នាក់។

(ប្រឡង Bacc II: ២០០៤)

៤. ប្រធានវិញ្ញាសាគណិតវិទ្យានៃការប្រឡងមួយមានលំហាត់ពីជគណិត 6 និងលំហាត់ធរណីមាត្រ 4។ បេក្ខជនម្នាក់ៗត្រូវធ្វើលំហាត់ 2 ក្នុងចំណោមលំហាត់ទាំង 10 នោះទៅតាមការជ្រើសរើសរបស់ខ្លួន។

ក. រកចំនួនករណីអាច។

ខ. រកប្រូបាបនៃព្រឹត្តិការណ៍ដូចតទៅ៖

A: សិស្ស x ម្នាក់ជ្រើសរើសយកលំហាត់ពីជគណិតទាំងពីរ។

B: សិស្ស y ម្នាក់ជ្រើសរើសយកលំហាត់ធរណីមាត្រទាំងពីរ។

C: សិស្ស z ម្នាក់ជ្រើសរើសយកលំហាត់ពីជគណិតមួយ និងលំហាត់ធរណីមាត្រមួយ។

(ប្រឡង Bacc II: ២០០៥)

៥. ក្នុងប្រអប់មួយមានថ្នាំគីណាល់ចំនួន 7គ្រាប់ និងថ្នាំអាស្ពីរីនចំនួន 5 គ្រាប់។ គេចាប់យកថ្នាំ 4 គ្រាប់ចេញពីប្រអប់ដោយចៃដន្យ។

ក. រកប្រូបាបដែលគេចាប់បានថ្នាំគីណាល់ទាំង 4គ្រាប់។

ខ. រកប្រូបាបដែលគេចាប់បានថ្នាំអាស្ពីរីនយ៉ាងតិច 1គ្រាប់។

(ប្រឡងឆមាសទី២: ២០០៦)

៦. គេប្រើលេខពី 0 ដល់ 9 ដើម្បីសរសេរចំនួនដែលមានលេខ 4 ខ្ទង់ ដោយខ្ទង់ដើមដំបូងមិនប្រើលេខ 0ទេ។

ក. តើគេអាចសរសេរបានប៉ុន្មានចំនួនខុសៗគ្នាតាមរបៀបខាងលើនេះ?

ខ. តើមានប៉ុន្មានចំនួនដែលមានលេខទាំង 4ខ្ទង់ខុសៗគ្នា។

គ. តើមានប៉ុន្មានចំនួនដែលមានលេខទាំង 4ខ្ទង់ដូចគ្នា?

(ប្រឡង Bacc II: ២០០៦)

**៧.** ថ្នាក់រៀនមួយមានសិស្ស 50នាក់។ ក្នុងការធ្វើសម្ភាសសិស្សទាំង 50នាក់ គេដឹងថាមានសិស្ស 30នាក់ចូលចិត្តរៀនគណិតវិទ្យា សិស្ស 25នាក់ចូលចិត្តរៀនរូបវិទ្យា និងសិស្ស 15នាក់ នាក់ចូលចិត្តរៀនគណិតវិទ្យានិងរូបវិទ្យា។ រកចំនួនសិស្សដែលៈ

ក. ចូលចិត្តរៀនគណិតវិទ្យា ឬរូបវិទ្យា។

ខ. មិនចូលចិត្តរៀនគណិតវិទ្យា និងមិនចូលចិត្តរៀនរូបវិទ្យា។

គ. ចូលចិត្តរៀនគណិតវិទ្យា តែមិនចូលចិត្តរៀនរូបវិទ្យា។

(ប្រឡងឆមាសទី 2: ២០០៧)

៨. ក្នុងប្រអប់មួយមានប៊ិចខៀវចំនួន 7ដើម ប៊ិចក្រហមចំនួន 5ដើម។ គេចាប់យកប៊ិច 4ដើមចេញពីប្រអប់ដោយចៃដន្យ។

ក. រកប្រូបាបដែលគេចាប់បានប៊ិចខៀវទាំង 4ដើម។

ខ. រកប្រូបាបដែលគេចាប់បានប៊ិចខៀវចំនួន 3ដើម និងប៊ិចក្រហមចំនួន 1 ដើម។

គ. រកប្រូបាបដែលមានគេចាប់បានប៊ិចក្រហមយ៉ាងតិច 1ដើម។

(ប្រឡងឆមាសទី2: ២០០៨)

៩. ក្រូចថ្លុង 20 ផ្លែដែលគេដាក់លក់មាន 16ផ្លែមានរស់ជាតិផ្អែម និង 4 ផ្លែទៀតមានរសជាតិជូរ។ អ្នកទិញម្នាក់ជ្រើសរើសយកក្រូច3ផ្លែដោយចៃដន្យ។រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោមនេះៈ

ក. A: ក្រូចទាំង 3ផ្លែសុទ្ធតែជូរ។

ខ. B: ក្រូចទាំង 3ផ្លែសុទ្ធតែផ្អែម។

គ. C: យ៉ាងតិចមានក្រូច 1ផ្លែមានរសជាតិផ្អែម។

(ប្រឡង Bacc II: ២០០៨)

**១០.** នៅក្នុងថង់មួយមានប៊ូលពណ៌ក្រហម ៨ និងប៊ូលពណ៌ខ្មៅ ៦។ គេចាប់យកប៊ូល 5ព្រមគ្នាចេញពីថង់ដោយចៃដន្យ។

ក. រកប្រូបាបដែលគេចាប់បានប៊ូលទាំង 5ពណ៌ក្រហមទាំងអស់។

ខ. រកប្រូបាបដែលគេចាប់បានប៊ូល 3ពណ៌ក្រហម និងប៊ូល 2ពណ៌ខ្មៅ។

គ. រកប្រូបាបដែលគេចាប់បានប៊ូលពណ៌ខ្មៅ 1យ៉ាងតិច។

(ប្រឡងឆមាសទី2: ២០០៩)

**១១.** មេបញ្ជាការកងទ័ពការពារព្រំដែនបានបង្កើតចំនួនសម្ងាត់ដែលជាចំនួនគត់មានលេខបីខ្ទង់ ហើយលេខទាំងបីខ្ទង់នោះខុសៗគ្នា ដោយប្រើលេខក្នុងចំណោមលេខពី 1ដល់ ៧។

ក. តើមេបញ្ជាការអាចបង្កើតចំនួនសម្ងាត់បានទាំងអស់ប៉ុន្មានរបៀបខុសៗគ្នា។

ខ. មេបញ្ជាការបានជ្រើសរើសយកចំនួនសម្ងាត់មួយដោយចៃដន្យ ដើម្បីប្រើការក្នុងពេលចេញប្រតិបត្តិការសឹក។ រកប្រូបាបនៃព្រឹត្តិការណ៍ៈ

A: «ចំនួនសម្ងាត់ជាចំនួនគត់គូ»។

B: «ចំនួនសម្ងាត់ជាចំនួនគត់សេស»។

(ប្រឡង Bacc II: ២០០៩)

**១២.** ទេសចរមួយក្រុមមានបុរស 3នាក់ និងស្ត្រី 5នាក់បានឈរបន្តគ្នាជាជួរដោយចៃដន្យ ដើម្បីទិញសំបុត្រចូលទស្សនាប្រាសាទអង្គរវត្ត។

ក. រកចំនួនរបៀបនៃការឈរបន្តគ្នាជាជួររបស់ក្រុមទេសចរនោះ។

ខ. រកប្រូបាបនៃព្រឹត្តិការណ៍នីមួយៗៈ

A: «ទេសចរដែលឈរនៅមុខគេបង្អស់ជាស្ត្រី»។

B: «ទេសចរជាបុរសទាំងអស់ឈរនៅជាប់ៗគ្នា»។

(ប្រឡង Bacc II: ២០១០)

**១៣.** ក្នុងថង់មួយមានឃ្លី 3 គ្រាប់គឺឃ្លី a ,b និង c ។ គេចាប់យកឃ្លីម្តង 1 គ្រាប់ចំនួនពីរលើកចេញពីថង់ដោយដាក់វិញ។

ក. ចូរកំណត់លំហសំណាក $S$ និងព្រឹត្តិការណ៍៖

$A$: «ចាប់បានឃ្លី 2គ្រាប់ផ្សេងគ្នា»

$B$: «ចាប់បានឃ្លី $b$ នៅលើកទី1»។

ខ. រកប្រូបាប : $P(A), P(B), P(A\cap B)$ និង $P(A\cup B)$

**(ប្រឡងឆមាសលើកទី២: ២០១១)**

**១៤.** ក្នុងថង់មួយមានប៊ិចក្រហម 8 និងប៊ិចខៀវ 6។ គេចាប់យកប៊ិច 5ព្រមគ្នាចេញពីថង់ដោយចៃដន្យ។ គណនាប្រូបាបនៃព្រឹត្តិការណ៍៖

$A$: «ប៊ិចទាំង 5ពណ៌ក្រហម»

$B$: «ប៊ិច 3ពណ៌ក្រហម និងប៊ិច 2ពណ៌ខៀវ»

$C$: «មានប៊ិចខៀវ 1យ៉ាងតិចក្នុងចំណោមប៊ិចទាំង 5»

**(ប្រឡង Bacc II ២០១១: ថ្នាក់វិទ្យាសាស្ត្រ)**

**១៥.** ក្នុងកាបូបមួយមានក្រដាសប្រាក់ 1000 ៛ ចំនួន 4 សន្លឹក និងក្រដាសប្រាក់ 500៛ ចំនួន 5 សន្លឹក។ គេហូតក្រដាសប្រាក់ 3 សន្លឹកចេញពីកាបូបដោយចៃដន្យ។

រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

1. $A$: «ហូតបានក្រដាសប្រាក់ 1000៛ ទាំង 3 សន្លឹក»
2. $B$: «ហូតបានក្រដាសប្រាក់500៛យ៉ាងតិច 1សន្លឹក»
3. $C$: «ហូតបានប្រាក់ចំនួន 2000 ៛»

**(ប្រឡងឆមាសលើកទី២: ២០១២ ថ្នាក់វិទ្យាសាស្ត្រ)**

**១៦.** គេចង់បង្កើតចំនួនមានលេខ 3 ខ្ទង់ ដែលខ្ទង់ទាំងបីមានលេខខុសៗគ្នាដោយយកចេញពី លេខ 1,2,3,4,5,67,8,9 ។

1. រកចំនួនករណីអាច។
2. រកប្រូបាបដែលចំនួនមានលេខ 3 នេះជាពហុគុណនៃ 5។
3. រកប្រូបាបដែលចំនួនមានលេខ 3 ខ្ទង់នេះជាចំនួនគូ។

**(ប្រឡងជាក់ខុបះ ២០១២ ថ្នាក់វិទ្យាសាស្ត្រ)**

**១៧.** នៅក្នុងប្រអប់ A មានសៀវភៅពីជគណិត 3 ក្បាល និងធរណីមាត្រ 4 ក្បាល ហើយប្រអប់ B មានសៀវភៅ ពីជគណិត 5 ក្បាល និងធរណីមាត្រ 3 ក្បាល។ គេចាប់យកសៀវភៅមួយពីប្រអប់ A ដាក់ចូលក្នុងប្រអប់ B រួចយកសៀវភៅមួយពីប្រអប់ B ដាក់ចូលក្នុងប្រអប់ Aវិញ។ រកប្រូបាបដែលចំនួនសៀវភៅទាំងពីជគណិត និងធរណីមាត្រនៅក្នុងប្រអប់ទាំងពីរមិនប្រែប្រួល។

(ប្រឡងឆមាសលើកទី២: ២០១៣ ថ្នាក់វិទ្យាសាស្ត្រ)

**១៨.** ក្នុងប្រអប់មួយមានឃ្លីពណ៌ស 2គ្រាប់ ដែលមានចុះលេខ 1,2 និងឃ្លីពណ៌ខ្មៅ 3 គ្រាប់ ដែលមានចុះលេខ 1,2,3។ រកចាប់យកឃ្លី 2 គ្រាប់ព្រមគ្នាដោយចៃដន្យពីក្នុងប្រអប់នោះ។

1. រកប្រូបាបនៃព្រឹត្តិការណ៍ A: «គេចាប់បានឃ្លីពណ៌ដូចគ្នា»។

2. រកប្រូបាបនៃព្រឹត្តិការណ៍ B: «គេចាប់បានឃ្លីមានផលបូកលេខស្មើ3»។

3. រកប្រូបាបនៃព្រឹត្តិការណ៍ C: «គេចាប់បានឃ្លីមានផលបូកលេខស្មើ 3 ដោយនឹងថាវាមានពណ៌ដូចគ្នា»។

(ប្រឡង Bac II: ២០១៣ ថ្នាក់វិទ្យាសាស្ត្រ)

**១៩.** នៅក្នុងថង់មួយគេមានប៊ូល 12 ដែលគេសរសេរ លេខពី 1 ដល់ 12។ គេចាប់យកប៊ូល 3 ព្រមគ្នាដោយចៃដន្យចេញពីថង់។

ក. រកប្រូបាបដែល «គេចាប់បានប៊ូលទាំង 3 មានលេខសុទ្ធតែចែកដាច់នឹង 3»។

ខ. រកប្រូបាបដែល «គេចាប់បានមានប៊ូលតែមួយគត់មានលេខចែកដាច់នឹង 3»។

គ. រកប្រូបាបដែល «គេចាប់បានមានលេខតាមលំដាប់ កើនជាស្វ៊ីតនព្វន្តដែលមានផលសងរួម $d=3$»។

(ប្រឡង Bac II: ២០១៤ ថ្នាក់វិទ្យាសាស្ត្រ)

២០. ក្នុងថ្នាក់រៀនមួយមានសិស្សអាស៊ី 4នាក់ សិស្សអាហ្វ្រិក 2 នាក់ សិស្សអឺរ៉ុប 3 នាក់។ គេរៀបចំជាក្រុមសិក្សា ក្នុងមួយក្រុមមានសិស្ស 3នាក់ ដោយចៃដន្យ។

រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

ក. «យ៉ាងតិចមានសិស្ស 2 នាក់ជាសិស្សអាស៊ី»

ខ. «យ៉ាងតិចមានសិស្ស 2 នាក់ជាសិស្សអឺរ៉ុប»

គ. «មានសិស្សម្នាក់ក្នុងមួយទ្វីប»។

(ប្រឡង Bacc II លើកទី២: ២០១៨ ថ្នាក់វិទ្យាសាស្ត្រ)

២១. ក្នុងស្បោងមួយមានប៊ូលពណ៌ស 3 ប៊ូលពណ៌ខៀវ 3 និងប៊ូលពណ៌ក្រហម 2។ គេចាប់យកប៊ូលម្ដង 3 ក្នុងពេលតែមួយចេញពីស្បោងដោយចៃដន្យ។ គេសន្និដ្ឋានថាប្រូបាបដែលចាប់បានប៊ូលនីមួយៗជាសមប្រូបាប។ គណនាប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

ក. A: «យ៉ាងតិចមានប៊ូល 2ពណ៌ខៀវ»។

ខ. B: «ប៊ូលទាំង 3 មានពណ៌ខុសៗគ្នា»។

(ប្រលង Bacc II ២០១៩ ថ្នាក់វិទ្យាសាស្ត្រ)

២២. ក្នុងថង់មួយមានប៊ូល 15 ដែលចែកជា ប៊ូលពណ៌បៃតងចំនួន 7 និងគេសរសេរលើប៊ូលទាំង 7 នេះតាមលេខរៀងពី 1ដល់ 7 រួចប៊ូលខៀវចំនួន 5 និងសរសេរលើប៊ូលទាំង 5នេះ តាមលេខរៀងពី 1ដល់ 5 ចុងក្រោយប៊ូលពណ៌ក្រហម 3 និងសរសេរលើប៊ូលទាំងនេះតាមលេខរៀងពី1ដល់ 3។ គេចាប់យកប៊ូលមួយចេញពីក្នុងថង់ដោយចៃដន្យ។ រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

A: ប៊ូលដែលចាប់បានមានពណ៌បៃតង។

B: ប៊ូលដែលចាប់បានមានលេខសេស។

C: ប៊ូលដែលចាប់បានមានពណ៌បៃតងនិងលេខសេស។

(ប្រលង Bacc II ២០១៦ ថ្នាក់វិទ្យាសាស្ត្រ)

សរសេរលើប៊ូលទាំង 7 នេះតាមលេខរៀងពី 1ដល់ 7 រួចប៊ូលខៀវចំនួន 5 និងសរសេរលើប៊ូលទាំង 5នេះ តាមលេខរៀងពី 1ដល់ 5 ចុងក្រោយប៊ូលពណ៌ក្រហម 3 និងសរសេរលើប៊ូលទាំងនេះតាមលេខរៀងពី1ដល់ 3។ គេចាប់យកប៊ូលមួយចេញពីក្នុងថង់ដោយចៃដន្យ។ រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

A: ប៊ូលដែលចាប់បានមានពណ៌បៃតង។

B: ប៊ូលដែលចាប់បានមានលេខសេស។

C: ប៊ូលដែលចាប់បានមានពណ៌បៃតងនិងលេខសេស។

(ប្រលង Bacc II ២០១៦ ថ្នាក់វិទ្យាសាស្ត្រ)

២៣.ក្នុងថ្នាក់រៀនមួយមានសិស្សពូកែចំនួន10នាក់ ដែលក្នុងនោះ4នាក់ជាសិស្សស្រី និង6នាក់ជាសិស្សប្រុស។ គេរៀបចំសិស្សជាក្រុម ក្នុងមួយក្រុមមានសិស្ស4នាក់ដោយចៃដន្យ យកទៅប្រកួតជាមួយក្រុមសិស្សនៃថ្នាក់ដទៃ។ រកប្រូបាបនៃព្រឹត្តិការណ៍:

A:«ក្រុមសិស្សដែលជ្រើសរើសបានសុទ្ធតែស្រី»

B:«ក្រុមសិស្សដែលជ្រើសរើសបានសុទ្ធតែប្រុស»

C:«ក្រុមសិស្សដែលជ្រើសរើសបាន50%ជាសិស្សប្រុស»។

(ប្រលង Bacc II ២០១៧ ថ្នាក់វិទ្យាសាស្ត្រ)

២៤.ក្នុងថង់មួយមានឃ្លីពណ៌សចំនួន2 ឃ្លីក្រហមចំនួន4 ឃ្លីពណ៌ខៀវចំនួន4។ គេចាប់យកឃ្លី3ព្រមគ្នាដោយចៃដន្យ។ រកប្រូបាបនៃព្រឹត្តិការណ៍:

A:«ឃ្លីទាំង3 មានពណ៌ក្រហម»

B:«យ៉ាងតិចមានឃ្លី2ពណ៌ខៀវ»

C:«ឃ្លីទាំង3មានពណ៌ខុសៗគ្នា»។

(ប្រលង Bacc II ២០១៨ ថ្នាក់វិទ្យាសាស្ត្រ)

២៥.ក្នុងថង់មួយមានប៊ូល16 ដែលគេសរសេរលេខពី1ដល់16។ គេចាប់យកប៊ូល3ចេញពីថង់ដោយចៃដន្យ។ រកប្រូបាបនៃព្រឹត្តិការណ៍:

A:«គេចាប់បានប៊ូលទាំងបីមានលេខសុទ្ធតែចែកដាច់នឹង4»

B:«គេចាប់បានប៊ូលទាំងបីមានលេខសុទ្ធតែមិនអាចចែកដាច់នឹង5»

C:«គេចាប់បានប៊ូលតែមួយគត់មានលេខចែកដាច់នឹង4»

(ប្រលង Bacc II ២០១៩ ថ្នាក់វិទ្យាសាស្ត្រ)